អគ្គិសនីកម្ពុជា
លេខ : ៤៧៧៤ សជណ.អក.រប

# សេចក្តីជូនដំណឹង
## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើស **បុគ្គលិក** ចំនួន **០៦ រូប** ដើម្បីចូលបម្រើការងារនៅ អគ្គិសនីកំពត នៃអគ្គិសនីកម្ពុជា ដូចខាងក្រោម :

*- **លក្ខណៈសម្បត្តិបេក្ខជន** :

១- សម្រាប់ **បុគ្គលិកប្រចាំការថែទាំបណ្តាញ MV (ស្នាក់ការជុំគិរី)** និង **បុគ្គលិកផ្នែកបណ្តាញ-ចែកចាយ** សរុបចំនួន ០៥ រូប :

- បេក្ខជនភេទប្រុស, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន ជាមធ្យម
- សម្រាប់បុគ្គលិកប្រចាំការថែទាំបណ្តាញ MV (ស្នាក់ការជុំគិរី) ផ្តល់អាទិភាពដល់បេក្ខជន ដែលមានអាសយដ្ឋានបច្ចុប្បន្ននៅស្រុកជុំគិរី ។

២- សម្រាប់ **អ្នកបើកបររថយន្តស្ទូច** ចំនួន ០១ រូប :

- បេក្ខជនភេទប្រុស, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតវប្បធម៌ : ចេះអាននិងសរសេរអក្សរខ្មែរ ឡើងទៅ, មានប័ណ្ណបើកបររថយន្តកម្រិត " ឃ២ " និង ចេះបើកបររថយន្តស្ទូច ។

***- ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជា បេក្ខជនត្រូវទាញយក (Download) ដោយផ្ទាល់ពីក្នុងគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើ ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជា ។**

*- **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

| | |
|---|---|
| - ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា | ចំនួន ០១ ច្បាប់ |
| - ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ | ចំនួន ០១ ច្បាប់ |
| - កិច្ចសន្យា សម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ | ចំនួន ០១ ច្បាប់ |
| - សលាកប័ត្របេក្ខជន | ចំនួន ០១ ច្បាប់ |
| - ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ មានបញ្ជាក់ពីអាជ្ញាធរដែនដី | ចំនួន ០១ ច្បាប់ |
| - តារាងពិន្ទុ (TRANSCRIPT) | ចំនួន ០១ ច្បាប់ |
| - ច្បាប់ចម្លងប័ណ្ណបើកបររថយន្ត កម្រិត " ឃ២ " (សម្រាប់ អ្នកបើកបររថយន្តស្ទូច) | ចំនួន ០១ច្បាប់ |

* - ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធI នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រលងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម ។

* - **ទីកន្លែងទទួលពាក្យ** : នៅអគារ B ជាន់ទី១ ការិយាល័យបុគ្គលិក នៃអគ្គិសនីកម្ពុជា
ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០ ។

* - **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្ដាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៦

**ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**
**អគ្គនាយករង**

**អេង_គន្ធា**

**បញ្ជាក់**
- សេចក្ដីជូនដំណឹងនេះ ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់ អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ "។